June 4, 2019

# ប្រតិភូពិសេសអឺរ៉ុបនឹងចុះមកស្វែងរកការពិតនៃបញ្ហាសិទ្ធិមនុស្សនៅកម្ពុជាជាលើកទី២ ចាប់ពីថ្ងៃស្អែក




លោក ចច អេដហ្គា ឯកអគ្គរដ្ឋទូតប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា © Phearak

**ដោយ វណ្ណ សុគន្ធា rfi 02/06/2019**

*គណៈប្រតិភូពិសេសរបស់សហភាពអឺរ៉ុបនឹងមកបំពេញទស្សនកិច្ចជាថ្មីនៅកម្ពុជាចាប់ពីថ្ងៃចន្ទ ទី០៣ មិថុនា ស្អែកនេះ ដើម្បីស្វែងរកការពិតពាក់ព័ន្ធបញ្ហាសិទ្ធិមនុស្ស មុនឈានទៅសម្រេចចុងក្រោយថាដកឬមិនដកប្រព័ន្ធអនុគ្រោះពន្ធ* EBA *ពីកម្ពុជា។ នេះ គឺជាដំណើរទស្សនកិច្ចស្វែងរកការពិតលើកទីពីររបស់សហភាពអឺរ៉ុបនៅកម្ពុជា ហើយវាបានគ្រោងធ្វើឡើងបន្ទាប់ពីសហភាពអឺរ៉ុបបានប្រកាសដាក់ចេញដំណើរការនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធ*EBA*បណ្ដោះអាសន្នកាលពីខែកុម្ភៈ។*

*គណៈប្រតិភូស្វែងរកការពិតរបស់សហភាពអឺរ៉ុប នឹងចាប់ផ្ដើមបេសកកម្មរបស់ខ្លួននៅកម្ពុជា ចាប់ពីថ្ងៃទី០៣ មិថុនា រហូតដល់ថ្ងៃទី០៧ មិថុនា ដើម្បីវិភាគនិងវាយតម្លៃពីស្ថានការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ជាពិសេស សិទ្ធិការងារ និងសិទ្ធិនយោបាយ។ នេះបើតាមការអះអាងឱ្យដឹងពីលោកមាជ សុវណ្ណារ៉ា អតីតមន្ត្រីជាន់ខ្ពស់អតីតគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃសៅរ៍។ ចំណែក ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា លោក* George Edgar *វិញ ក៏បានបញ្ជាក់ឱ្យដឹងពីដំណើរទស្សនកិច្ចនេះដែរ តាមរយៈសារព័ត៌មានក្នុងស្រុកមួយកាលពីថ្ងៃសុក្រ។ បើតាមលោក* George

Edgar ដំណើរទស្សនកិច្ចស្វែងរកការពិតជាថ្មីនេះ គឺជាផ្នែកមួយនៃដំណើរការទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងកម្ពុជា ក្នុងបរិបទនៃប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)។

អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា លោកផៃ ស៊ីផាន អះអាងថា រដ្ឋាភិបាលកម្ពុជា មិនបានព្រួយបារម្ភចំពោះការមកប្រមូលព័ត៌មានជាថ្មីរបស់សហភាពអឺរ៉ុបនេះឡើយ ព្រោះរដ្ឋាភិបាលកម្ពុជាធ្លាប់បានបកស្រាយការពិតអស់ហើយដល់គណៈប្រតិភូសហភាពអឺរ៉ុបនេះ ដែលបានមកកម្ពុជាលើកមុនៗ ដូច្នេះ សម្រាប់ការមកជាថ្មីនេះ លោកផៃ ស៊ីផាន បានលើកឡើងថា វាហាក់ស្ថិតក្នុងរូបភាពនយោបាយ ជាជាងលទ្ធិប្រជាធិបតេយ្យ។

សូមជម្រាបជូនថា ដំណើរមកដល់ជាបន្តបន្ទាប់នៃគណៈប្រតិភូសហភាពអឺរ៉ុបនេះ ធ្វើឡើងក្រោយពីអឺរ៉ុបបានប្រកាសដាក់ចេញនូវដំណើរការនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធ (EBA) ពីកម្ពុជា កាលពីខែកុម្ភៈកន្លងទៅ។ តាមនីតិវិធី ដំណើរការនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធ (EBA) ត្រូវធ្វើឡើងជា ៣ដំណាក់កាល។ ដំណាក់កាលទីមួយ មានរយៈពេល ៦ខែ គឺជាពេលវេលាសម្រាប់តាមដាន ប្រមូលព័ត៌មាន និងចរចាជាមួយភាគីរដ្ឋាភិបាលកម្ពុជា។ ដំណាក់កាលទីពីរ មានរយៈ៦ខែ ដោយចែកចេញជាពីរផ្នែក គឺ ៣ខែ សម្រាប់សរសេររបាយការណ៍ និង ៣ខែទៀត សម្រាប់ស្តាប់ចម្លើយតបពីភាគីកម្ពុជា និងឈានទៅសម្រេចថាតើសហភាពអឺរ៉ុប ត្រូវព្យួរ ឬមិនព្យួរ EBA។ ចំណែក ដំណាក់កាលចុងក្រោយ ប្រសិនបើសហភាពអឺរ៉ុបសម្រេចព្យួរEAB នោះ គេត្រូវទុកពេល ៦ខែទៀត ទើបសេចក្តីសម្រេចនេះចូលជាធរមានបាន៕